**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ (ភ្ជាប់ជាមួយឧបសម្ព័ន្ធដែលជាឯកសារសម្ងាត់)

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Feb-2011, 14:56
CMS/CFO: Ly Bunloung

---

## សេចក្តីសង្ខេបអំពីបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំ

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

លោក Andrew IANUZZI

លោក Jasper PAUW

លោក ព្រំ ផល្លា

Göran SLUITER

Annebrecht VOSSENBERG (កម្មសិក្សាការីច្បាប់)

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៨០(២) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ក.ក ("វិធានផ្ទៃក្នុង") និង ដីការបស់អង្គជំនុំជម្រះសាលាដំបូង បង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ "ដីកាបង្គាប់ស្តីពីការរៀបចំសវនាការ"[១] ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា (មេធាវីការពារក្តី) សូមដាក់សារណាសង្ខេបរបស់ខ្លួនស្តីពីបញ្ជីឈ្មោះសាក្សី[២] អ្នកជំនាញ[៣] និងដើមបណ្តឹងរដ្ឋប្បវេណី[៤] (ជារួមហៅថា "សារណាសង្ខេបរបស់មេធាវីការពារក្តី"។ អនុលោមតាមដីកាបង្គាប់ស្តីពីការរៀបចំសវនាការ ឯកសារទាំងនេះត្រូវបានដាក់ជូនទាន់ពេលវេលា[៥]។ បន្ថែមលើនេះទៅទៀត មេធាវីការពារក្តីសូមដាក់ជូននូវសារណាខាងក្រោមនេះ។

## II. សារណា

### ក. ការកត់សម្គាល់ទូទៅ និងការបដិសេធ

២. ចំពោះសំអាងហេតុដែលបានលើកឡើងកាលពីមុនរួចមកហើយនោះ[៦] មេធាវីការពារក្តីសូមរក្សាសិទ្ធិរបស់ខ្លួនដើម្បីដាក់ឯកសារបន្ថែម និង/ឬ កែប្រែឯកសារសារណាសង្ខេបរបស់មេធាវីការពារក្តី *នៅពេលណាមួយ* ស្របតាមការណែនាំបន្ថែមពីជនជាប់ចោទ។ បន្ថែមលើនេះទៅទៀត មេធាវីការពារក្តីសូមបញ្ជាក់សាជាថ្មីថា មេធាវីការពារក្តីបានដាក់អញ្ញត្រកម្មទាក់ទងនឹង

---

[១] ឯកសារលេខ **E-9** "ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ "ដីកាបង្គាប់ស្តីពីការរៀបចំសវនាការ" ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ERN 00635754–00635759 ពីកថាខណ្ឌ ៦ ដល់ ៧។

[២] ត្រូវបានភ្ជាប់មកជាមួយនេះជា ឧបសម្ព័ន្ធ ឃ។

[៣] ត្រូវបានភ្ជាប់មកជាមួយនេះជា ឧបសម្ព័ន្ធ ង។

[៤] ត្រូវបានភ្ជាប់មកជាមួយនេះជា ឧបសម្ព័ន្ធ ច។

[៥] *សម្គាល់៖* អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ថា សារណាសង្ខេបបែបនេះមិនត្រូវដាក់ឲ្យហួសពីថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ នោះឡើយ "ដីកាបង្គាប់ស្តីពីការរៀបចំសវនាការ" កថាខណ្ឌ ៦។

[៦] *សូមមើល* ឯកសារលេខ **E-9/4/4** "បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំ" ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ERN 00644417–00644423 "បញ្ជីឈ្មោះសាក្សីដែលដាក់ដោយមេធាវីការពារក្តី" កថាខណ្ឌ ២។

នីត្យានុកូលភាពនៃវិធានផ្ទៃក្នុងរួចមកហើយ[៧]។ ដោយសារអញ្ញត្រកម្មនេះមិនបានលើកឡើងឲ្យបានច្បាស់លាស់អំពីវិធាន ៨០(៣)(ក) នោះមេធាវីការពារក្តីសូមស្នើថា បទប្បញ្ញត្តិបែបនេះ (និងនិយាយឲ្យទូលំទូលាយទៅ កថាខណ្ឌទីប្រាំមួយ (៦) នៃដីកាបង្គាប់ស្តីពីការរៀបចំសវនាការ) មិនមានមូលដ្ឋានគតិយុត្តិឡើយ[៨]។ ទោះជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីយល់ឃើញថា ឯកសារដែលបានដាក់ជូនរហូតមកទល់នឹងថ្ងៃនេះ គឺស្របទៅនឹងកាតព្វកិច្ចរបស់ខ្លួន ដែលស្ថិតនៅក្រោមច្បាប់កម្ពុជា និងសូមរក្សាសិទ្ធិរបស់ខ្លួនដើម្បីជំទាស់តវ៉ាទៅនឹងវិធានណាមួយនៃវិធានផ្ទៃក្នុង ដែលងាកចេញទាំងខុសច្បាប់ ពីនីតិវិធីដែលបានបង្កើតនៅក្នុងក្របខ័ណ្ឌជាតិ[៩]។ ជាចុងក្រោយ មេធាវីការពារក្តីសូមរំលឹកដល់អង្គជំនុំជម្រះសាលាដំបូងថា មេធាវីការពារក្តីមានបំណងដាក់សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម ទៅលើបញ្ហាដែលបានបញ្ជាក់ជូនក្នុងសារណាសង្ខេបរបស់មេធាវីការពារក្តី មុនការចាប់ផ្តើមសវនាការបឋម[១០]។

## III. ការបកប្រែភាសា

៣. យោងតាមការរាំងស្ទះនាពេលបច្ចុប្បន្ន (និងនៅតែបន្តមាន) របស់អង្គភាពបកប្រែភាសា មេធាវីការពារក្តីមិនអាចដាក់ឯកសារបកប្រែជាភាសាខ្មែរនៃឧបសម្ព័ន្ធ ដែលភ្ជាប់មកជាមួយនឹងសារណាសង្ខេបនេះបានទេ។ ការបកប្រែឯកសារទាំងនេះកំពុងតែបន្តធ្វើ ហើយឯកសារជាភាសាខ្មែរនឹងត្រូវដាក់ជូន ទៅតាមពេលវេលាជាក់ស្តែង ឲ្យបានឆាប់បំផុត[១១]។

---

[៧] *សូមមើល* ឯកសារលេខ **E-36** "អញ្ញត្រកម្មទាក់ទងនឹងនីត្យានុកូលភាពនៃវិធានផ្ទៃក្នុង និងអានុភាពនៃដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ និងចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១១ ERN 00642561–00642576 "វិធានផ្ទៃក្នុងស្តីពីអញ្ញត្រកម្ម"។ *សម្គាល់៖* ដោយអនុលោមតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារនេះនឹងត្រូវដាក់ឡើងវិញ (ជាផ្នែកមួយនៃអញ្ញត្រកម្មរួមបញ្ចូលគ្នារបស់មេធាវីការពារក្តី) នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ។

[៨] *សូមមើល* វិធានផ្ទៃក្នុងស្តីពីអញ្ញត្រកម្ម។

[៩] *ដូចខាងលើ*។

[១០] *សូមមើល* វិធាន ៩៣(១) នៃវិធានផ្ទៃក្នុង (ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់នោះ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា)។

[១១] *សម្គាល់៖* មន្ត្រីច្បាប់ជាន់ខ្ពស់បានទទួលការជូនដំណឹង តាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង។ សូមមើល ឯកសារលេខ **E-38** អនុស្សរណៈពីលោក ស្រី Susan Lamb ផ្ញើជូនភាគីទាំងអស់ សំណុំរឿង ០០២ កម្មវត្ថុ៖ "នីតិវិធីបណ្តោះសារណាសង្ខេបអំពីបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី

## គ. ព័ត៌មានពាក់ព័ន្ធនឹងសាក្សីនីមួយៗដែលបានស្នើសុំ

៤. មេធាវីការពារក្ដីបានខិតខំប្រឹងប្រែងតាមលទ្ធភាពដែលអាចធ្វើទៅបាន និងដោយសុចរិត ដើម្បីដាក់ជូនឯកសារ ដែលអង្គជំនុំជម្រះសាលាដំបូងបានស្នើសុំនៅត្រង់កថាខណ្ឌទីប្រាំមួយ (៦) នៃដីកាបង្គាប់ស្ដីពីការរៀបចំសវនាការ។ ប៉ុន្តែ ដូចបានលើកឡើងរួចមកហើយ[១២] មេធាវីការពារក្ដីមិនស្ថិតនៅក្នុងតួនាទីមួយដើម្បីប្រមូលព័ត៌មានសំខាន់ៗពីបុគ្គលទាំងឡាយ ដែលមេធាវីការពារក្ដីមានបំណងស្ដាប់ចម្លើយពួកគាត់ក្នុងនាមជាសាក្សីនោះទេ។ អាស្រ័យហេតុនេះ ព័ត៌មានដែលបានផ្ដល់ជូនមកទល់នឹងថ្ងៃនេះ គឺយោងទៅលើការវាយតម្លៃដ៏ប្រសើរបំផុតរបស់មេធាវីការពារក្ដី។ ក្នុងន័យនេះ មេធាវីការពារក្ដីយល់ឃើញថា ព័ត៌មានបែបនេះគឺត្រូវគ្នាទៅនឹងកាតព្វកិច្ចរបស់ខ្លួន នៅក្រោមច្បាប់កម្ពុជា[១៣]។ នៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីនេះ មេធាវីការពារក្ដីមិនស្ថិតនៅក្នុងតួនាទីមួយដើម្បីផ្ដល់ការវាយតម្លៃប្រកបដោយអត្ថន័យណាមួយ ទាក់ទងនឹងរយៈពេលនៃការផ្ដល់សក្ខីកម្មរបស់សាក្សីដែលបានស្នើសុំនោះទេ។ ព័ត៌មានបែបនេះ នឹងត្រូវផ្ដល់ជូននៅពេលណាដែលមេធាវីការពារក្ដីទទួលបាន)។ ដូចបានលើកឡើងពីមុនរួចមកហើយ ឈ្មោះសាក្សីជាច្រើនដែលបានដាក់បញ្ចូលក្នុងបញ្ជីឈ្មោះសាក្សីក៏អាចមានលក្ខណៈសម្បត្តិជាអ្នកជំនាញបានដែរ ហើយមេធាវីការពារក្ដីអាចអញ្ជើញអ្នកទាំងនោះធ្វើជាអ្នកជំនាញបាន នៅពេលសវនាការ[១៤]។

## ឃ. ប្រភេទ និងសំអាង

៥. នៅក្រោមចំណងជើងថា "ចំណុចនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ" មេធាវីការពារក្ដីបានចង្អុលបង្ហាញប្រភេទផ្សេងៗគ្នាមួយចំនួន ទាក់ទងទៅនឹងសក្ខីកម្មរបស់សាក្សីដែលបានស្នើសុំនេះ។ ក្រៅពីចំណុចទាំងឡាយដែលជាប់ទាក់ទងគ្នាយ៉ាងខ្លាំងទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឧទាហរណ៍ដូចជា មូលដ្ឋានបទល្មើស "crime bases" និងមន្ទីរសន្តិសុខនានា អត្ថិភាពនៃជម្លោះប្រដាប់អាវុធ ការចូលរួម និង/ឬ ការដឹងឮរបស់លោក នួន ជា ចំពោះសកម្មភាពឧក្រិដ្ឋ និងរចនាសម្ព័ន្ធបញ្ជា

---

អាសន្ននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងករណីមានការជាប់គាំងការបកប្រែភាសា ធ្វើឲ្យភាគីមិនអាចដាក់ជូនឯកសារតាមពេលវេលាកំណត់បាន" ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ERN 00643388–00643388។

[១២] *សូមមើល* បញ្ជីឈ្មោះសាក្សីដែលដាក់ដោយមេធាវីការពារក្ដី កថាខណ្ឌ ៦។

[១៣] *សូមមើល* វិធានផ្ទៃក្នុងស្ដីពីអញ្ញត្រកម្ម។

[១៤] *សូមមើល* បញ្ជីឈ្មោះសាក្សីដែលដាក់ដោយមេធាវីការពារក្ដី កថាខណ្ឌ ១៤។

របស់បក្សកុម្មុយនីស្តកម្ពុជា) មេធាវីការពារក្តីបានកំណត់ប្រធានបទសំខាន់ៗមួយចំនួនទៀត (មិននិយាយថាចាំបាច់បំផុតនោះទេ) ដែលត្រូវតែដោះស្រាយនៅក្នុងសវនាការដែលស្របច្បាប់ និងប្រកបដោយយុត្តិធម៌ ដែលក្នុងនោះរួមមាន ប៉ុន្តែ មិនកំណត់ត្រឹមតែ៖

ក. ការបង្កើត និងរចនាសម្ព័ន្ធរបស់តុលាការនេះ។

ខ. ការជ្រើសរើស ការតែងតាំង ឯករាជ្យភាព អនាគតិភាព និងសុចរិតភាពរបស់តុលាការ។

គ. ការជ្រើសរើសបេក្ខជនដើម្បីធ្វើការផ្តន្ទាទោស។

ឃ. គុណភាព និងវិសាលភាពនៃកិច្ចស៊ើបសួរ (រួមទាំង ការជ្រើសរើស ការបញ្ជាក់ និងយថាភូតនៃភស្តុតាង)។

ង) ការជ្រៀតជ្រែកខាងនយោបាយចូលក្នុងដំណើរការរបស់តុលាការ (រួមទាំង ការជ្រៀតជ្រែកមកលើសាក្សី និងការចោទប្រកាន់ពីអំពើពុករលួយ)។

ច) ជំនឿទុកចិត្តរបស់សាក្សីបដិបក្ខ (ជាពិសេស ឌុច)។

ឆ) តួនាទីរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម។

ជ) គោលបំណងជាវិជ្ជមានរបស់បក្សកុម្មុនីស្តកម្ពុជា (ប.ក.ក) និង

ឈ) ជម្រើសនៃរចនាសម្ព័ន្ធបញ្ជារបស់ ប.ក.ក

ញ) ស្ថានភាពគ្របដណ្តប់មកលើប្រទេសកម្ពុជាមុនឆ្នាំ ១៩៧៥ និងបុព្វហេតុនានា (ដោយរួមបញ្ចូលទាំងការពាក់ព័ន្ធរបស់សេអ៊ីអា អាមេរិក ក្នុងយុទ្ធនាការទម្លាក់គ្រាប់បែក ការបណ្តាលឲ្យមានវិបត្តិជនភៀសខ្លួន ស្ថានភាពរស់នៅរបស់ប្រជាជនក្នុងរបបសាធារណរដ្ឋខ្មែរ)។

ក្នុងន័យនេះ យុត្តិសាស្ត្រអន្តរជាតិត្រូវបានយកមកបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង ដែលយុត្តិសាស្ត្រនេះបញ្ជាក់ថា "អំពើដែលបានប្រព្រឹត្តមុនយុត្តាធិការពេលវេលា អាចនឹងត្រូវយកមកធ្វើជាសំអាង ក្នុងករណីដែលមានគោលការណ៍យកភស្តុតាងនោះមក "ធ្វើការបញ្ជាក់ពីបរិបទដែល

កើតមានឡើងនេះ"[១៥]។

៦. មិនទាន់មានការបញ្ជាក់ណាមួយ ត្រូវបានធ្វើឡើងទៅនឹងការអះអាងរបស់បុគ្គលណាម្នាក់ទៅលើបុគ្គលម្នាក់ទៀតនោះទេ នៅពេលដែលឈ្មោះជាច្រើន ត្រូវបានស្នើសុំដោយមេធាវីការពារក្តីនៅក្រោមប្រភេទនីមួយៗដែលបានរៀបរាប់ខាងលើនេះ។ នេះគឺជាការខកខានដោយចេតនា ហើយមេធាវីការពារក្តីសំណូមពរថា នៅក្នុងចំណោមបញ្ហាជាច្រើន បញ្ហានៃការជ្រើសរើសសាក្សី និងសំអាង គួរតែចងក្រងជាតារាងសម្រាប់ការពិភាក្សាដេញដោលល្អិតល្អន់ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការខាងមុខនេះ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង បដិសេធមិនចេញសេចក្តីសម្រេចសំខាន់*ណាមួយ*ទាក់ទងទៅនឹងបញ្ជីឈ្មោះសាក្សីដែលដាក់ដោយមេធាវីការពារក្តី និង/ឬ សារណាសង្ខេបរបស់មេធាវីការពារក្តី នៅមុនកិច្ចប្រជុំនេះទេ នោះមេធាវីការពារក្តីស្នើសុំឲ្យផ្តល់ឱកាសដើម្បីដាក់សារណាជាលាយលក្ខណ៍អក្សរបន្ថែមទៀត។

## III. សេចក្តីសន្និដ្ឋាន

៧. នៅមានខ្លឹមសារមួយចំនួនទៀតដែលមិនទាន់បានលើកឡើងឲ្យចប់សព្វគ្រប់។ អាស្រ័យហេតុនេះ មេធាវីការពារក្តី សូមរក្សាសិទ្ធិទាំងអស់ដែលលោក នួន ជា អាចទទួល នៅក្រោមច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ក្នុងការដាក់សារណាបន្ថែមតាមការចាំបាច់។

សហមេធាវីការពាររបស់លោក នួន ជា

| | | |
|---|---|---|
| លោក សុន អរុណ | លោក Michiel PESTMAN | លោក Victor KOPPE |

---

[១៥] *សូមមើល* ឯកសារ D-365/2/1 "សារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ឆ្លើយតបទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីការសុំដាក់ឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលគាំទ្រដល់ការបញ្ជាក់ពីការដឹងឮរបស់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្មទាំងនោះ" ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១០ ERN 00508881–00508908 កថាខណ្ឌ ១១ (ដកស្រង់ពីឯកសារលេខ **D-300** "ដីកាសម្រេចលើសំណើសុំ D-153, D-172, D-174, D-178 និង D-284" ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០ ERN 00428047–00428058 កថាខណ្ឌ ៩ (ដែលចង្អុលបង្ហាញពីសំណុំរឿងលេខ ICTR-99-52-A *រដ្ឋអាជ្ញា តទល់នឹង* Nahimana *និងអ្នកផ្សេងទៀត* សាលដីកា ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៣១៥)។ *សូមមើលផងដែរ* បញ្ជីឈ្មោះសាក្សីដែលដាក់ដោយមេធាវីការពារក្តី កថាខណ្ឌ ១២។